**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល**

**ស្តីពី**

**ការរកឃើញ ១១ ករណីថ្មីទៀត ជាបុរសជនជាតិខ្មែរឥស្លាមដែលវិលត្រឡប់មកពីចូលរួមពិធីសាសនា នៅប្រទេសម៉ាឡេស៊ី និងបុរសជនជាតិខ្មែរ ០១ នាក់ត្រឡប់មកពីប្រទេសថៃ វិជ្ជមានវីរុសកូវីដ១៩**

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានបង្ហាញ វិជ្ជមានវីរុសកូវីដ១៩ ចំនួន១២នាក់ ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

**១. នៅខេត្តបន្ទាយមានជ័យ៖ ០២ ករណី**

- បុរសជនជាតិខ្មែរឥស្លាម១នាក់ វិជ្ជមានកូវីដ១៩ នៅក្រុងសេរីសោភ័ណ

- បុរសជនជាតិខ្មែរ១នាក់មកពីប្រទេសថៃ នៅភូមិព្រៃឬស្សី ក្រុងសេរីសោភ័ណ មានលទ្ធផលតេស្តវិជ្ជមានវីរុសកូវីដ១៩

បុរសទាំងពីរនាក់ខាងលើនេះ ត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តបន្ទាយមានជ័យរួចហើយ។

**២. នៅរាជធានីភ្នំពេញ៖ ០២ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០២នាក់ (អាយុ ៦៣ឆ្នាំម្នាក់ និងអាយុ ៦៤ឆ្នាំម្នាក់) នៅព្រែកប្រា មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៣. នៅខេត្តកំពង់ឆ្នាំង៖ ០២ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០២នាក់ (អាយុ ៧៥ឆ្នាំម្នាក់ និងអាយុ ២៨ឆ្នាំម្នាក់) មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។

**៤. នៅបាត់ដំបង៖ ០៤ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០៤នាក់ (អាយុ ៣៨ឆ្នាំ ដល់ ៤៥ឆ្នាំ) មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តបាត់ដំបង។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: [illegible] ៨៨៤ ៩០៩

**៥. នៅខេត្តកំពត៖ ០១ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០១នាក់ (អាយុ ៣០ឆ្នាំ) មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកែប ដោយសារគាត់ជាអ្នកបកប្រែឲ្យម៉ាឡេធ្វើការនៅកែប។

**៦. នៅខេត្តត្បូងឃ្មុំ៖ ០១ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០១នាក់ (អាយុ ៦១ឆ្នាំ) មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តនៅពញាក្រែក។

*សម្គាល់៖ បុរសជនជាតិឥស្លាមទាំង១១នាក់ខាងលើនេះ ជាអ្នកក្នុងចំណោមអ្នកដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ីសរុបចំនួន ៧៩នាក់។*

ក្រុមឆ្លើយតបបន្ទាន់និងក្រុមគ្រូពេទ្យថ្នាក់ជាតិនិងក្រោមជាតិ កំពុងបន្តតាមដានរកអ្នកប៉ះពាល់យ៉ាងសកម្ម ជាពិសេសអ្នកដែលបានចូលរួមនៅក្នុងពិធីសាសនាឥស្លាម នៅប្រទេសម៉ាឡេស៊ីកន្លងមកនេះបន្ថែមទៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩